**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យ សត្វ សាច់ និង ផលិតផលសត្វ

* * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦០០ / ០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និង សេវា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពី ការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពី ការបន្ថែមមុខងារការកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៧

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ការគ្រប់គ្រងសត្តឃាតដ្ឋាន សកម្មភាពអាជីវកម្មពិឃាតសត្វ ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និង កន្លែងតាំងលក់ ក្នុងគោលបំណង ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺសត្វ ការពារសុខភាពសត្វ ធានាគុណភាពផលិតផល និង ការពារសុខភាពសាធារណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា។

មិនអនុញ្ញាតឱ្យមានការពិឃាតសត្វយកសាច់ នៅរៀងរាល់ថ្ងៃឧបោសថសីល នៅតាមសត្តឃាតដ្ឋានទាំងអស់ ដោយយោងតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថាព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។

**មាត្រា ២.-**

ការគ្រប់គ្រងសត្តឃាតដ្ឋាន សកម្មភាពអាជីវកម្មពិឃាតសត្វ ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

**មាត្រា ៣.-**

ពាក្យបច្ចេកទេសដែលប្រើប្រាស់សម្រាប់អនុក្រឹត្យនេះមានដូចខាងក្រោម÷

- **កន្លែងតាំងលក់:** សំដៅដល់កន្លែងដាក់លក់សាច់ និង ផលិតផលសត្វ នៅគ្រប់ទីកន្លែង
- **កន្លែងបង្ខាំងសត្វ:** សំដៅដល់កន្លែងរក្សាទុកសត្វ រយៈពេលពី ១២ (ដប់ពីរ) ទៅ ២៤ (ម្ភៃបួន) ម៉ោង ដើម្បីឱ្យសត្វសម្រាក និង ធ្វើការត្រួតពិនិត្យសុខភាពមុនពិឃាត ដោយភ្នាក់ងារបសុពេទ្យ
- **ត្រាបសុពេទ្យ:** សំដៅដល់ប្រដាប់ មានស្លាកចម្លាក់ជាគ្រឿងសម្គាល់ របស់អង្គភាពផលិតកម្ម និង បសុព្យាបាលមានសមត្ថកិច្ច សម្រាប់បោះ ឬ អូសលើផ្ទាំងសាច់ ក្រោយពេលត្រួតពិនិត្យអនាម័យសាច់ ដែលបញ្ជាក់ថា ផលិតផលនោះមានអនាម័យ គ្មានមេរោគបង្កជំងឺ និង មិនប៉ះពាល់សុខភាពសាធារណៈ
- **ផលិតផលសត្វ:** សំដៅដល់ឈាម គ្រឿងក្នុង ឆ្អឹង រោម ស្បែក ស្លាប ស្នែង ក្រចក លាមក ទឹកនោម និង កាកសំណល់ផ្សេងៗទៀត របស់សត្វដែលបានពិឃាត
- **ភ្នាក់ងារបសុពេទ្យ:** សំដៅដល់មន្ត្រីបសុពេទ្យ ដែលត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និង កន្លែងតាំងលក់

- **ភិនសត្វ:** សំដៅដល់ប័ណ្ណចេញដោយអង្គភាពផលិតកម្ម និង បសុព្យាបាលមានសមត្ថកិច្ច ដើម្បីសម្គាល់ភិនភាគសត្វចតុប្បាទ ដោយបញ្ជាក់ពីប្រភេទសត្វ ភេទ អាយុ សម្បុរ ពូជ កម្ពស់ ស្នែង ក្រយៅ និង ស្លាកស្នាមផ្សេងៗ
- **វិញ្ញាបនបត្រអនាម័យសត្វ:** សំដៅដល់លិខិតចេញដោយសមត្ថកិច្ចផលិតកម្ម និង បសុព្យាបាល ពីប្រភពដើមដែលសត្វនោះរស់នៅ ដើម្បីដឹកជញ្ជូនមកសត្តឃាតដ្ឋាន ។ វិញ្ញាបនបត្រនេះផ្តល់ឱ្យបន្ទាប់ពីបានធ្វើការត្រួតពិនិត្យសត្វ តាមលក្ខណៈបច្ចេកទេសបសុពេទ្យ ឃើញថាមានសុខភាពល្អ និង គ្មានមេរោគបង្កជំងឺឆ្លង
- **វិញ្ញាបនបត្របញ្ជាក់អនាម័យសាច់ និង ផលិតផលសត្វ :** សំដៅដល់លិខិត ដែលចេញដោយភ្នាក់ងារបសុពេទ្យប្រចាំនៅសត្តឃាតដ្ឋាន ក្រោយពីបានធ្វើការត្រួតពិនិត្យ ឬ វិភាគលើសាច់ និង ផលិតផលសត្វ ឃើញថា មានគុណភាពល្អ គ្មានមេរោគបង្កជំងឺឆ្លងសត្វ និង មិនប៉ះពាល់ដល់សុខភាពសាធារណៈ តាមលក្ខណៈបច្ចេកទេសបសុពេទ្យ
- **វិធានបសុពេទ្យ:** សំដៅដល់ការធ្វើអនាម័យសត្តឃាតដ្ឋាន ការសម្លាប់មេរោគ ធ្វើអនាម័យ ការកែច្នៃ បញ្ចេញចោល កាត់ផ្តាច់មិនឱ្យឆ្លងបាន សម្លាប់ចោល កប់ ឃាត់ទុក បង្វែរទិសដៅប្រើប្រាស់ ឬ ដុតបំផ្លាញចោល សត្វ សាច់ និង ផលិតផលសត្វ ដែលគ្មានអនាម័យ ផ្ទុកមេរោគ ឬ មានជំងឺ
- **សាច់:** សំដៅដល់ផ្នែកទាំងអស់នៃសត្វ ដែលអាចបរិភោគបាន លើកលែងតែផលិតផលសត្វ ដែលមានចែងក្នុងអនុក្រឹត្យនេះ
- **សាច់ ផលិតផលសត្វមានរោគ :** សំដៅដល់សាច់ និង ផលិតផលសត្វ ដែលផ្ទុកទៅដោយមេរោគដូចជាៈ វីរុស បាក់តេរី ប៉ារ៉ាស៊ីត ផ្សិត និង ប្រភេទអតិសុខុមប្រាណផ្សេងៗទៀត
- **សត្តឃាតដ្ឋាន:** សំដៅដល់កន្លែងប្រមូលផ្តុំសម្លាប់សត្វជាប្រចាំ ដើម្បីយកសាច់ធ្វើអាជីវកម្ម ឬម្ហូបអាហារ ដោយធានាគុណភាពអនាម័យ
- **កម្រៃត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ:** សំដៅដល់ចំនួនទឹកប្រាក់ ដែលអាជីវករត្រូវបង់កម្រៃ លើការបម្រើសេវាកម្មត្រួតពិនិត្យ សត្វ សាច់ និង ផលិតផលសត្វ
- **សត្វផ្ទុកមេរោគ:** សំដៅដល់សត្វដែលមានផ្ទុកមេរោគ ដោយពុំទាន់បង្ហាញរោគសញ្ញា ប៉ុន្តែអាចពិនិត្យឃើញតាមរយៈការវិភាគនៅមន្ទីរពិសោធន៍
- **សត្វមានជំងឺ:** សំដៅដល់សត្វដែលបានបង្ហាញរោគសញ្ញាច្បាស់លាស់ ។ រោគសញ្ញាអាចពិនិត្យឃើញដោយផ្ទាល់ ឬ តាមការវិភាគនៅមន្ទីរពិសោធន៍

- **សំណាកសម្រាប់ធ្វើវិភាគ:** សំដៅដល់ផ្នែកមួយរបស់សត្វ សាច់ ឬ ផលិតផលសត្វ ដែលត្រូវបានយកសម្រាប់ពិនិត្យ និង វិភាគនៅមន្ទីរពិសោធន៍
- **ស្លាកបសុពេទ្យ:** សំដៅដល់ស្លាក ឬ តែមប្រើបសុពេទ្យរបស់អង្គភាពផលិតកម្ម និង បសុព្យាបាល បិទសម្គាល់លើកញ្ចប់សាច់ និង ផលិតផលសត្វ ក្រោយពេលត្រួតពិនិត្យដែលបញ្ជាក់ថា មានអនាម័យ គ្មានមេរោគបង្កជំងឺ និង មិនប៉ះពាល់សុខភាពសាធារណៈ
- **អត្តសញ្ញាណប័ណ្ណសត្វ:** សំដៅដល់ប័ណ្ណចេញដោយអង្គភាពផលិតកម្ម និង បសុព្យាបាលមានសមត្ថកិច្ច ដើម្បីសម្គាល់លក្ខណៈសត្វចតុប្បាទ ធំ តូច និង បក្សី
- **អាជីវកម្មពិឃាតសត្វ :** សំដៅដល់ការពិឃាតសត្វយកសាច់ និង ផលិតផលសត្វសម្រាប់ធ្វើពាណិជ្ជកម្ម ។

## ជំពូកទី ២
## ការគ្រប់គ្រងសត្តឃាតដ្ឋាន និង ការធ្វើអាជីវកម្មពិឃាតសត្វ

មាត្រា ៤.-

សត្តឃាតដ្ឋានត្រូវបានធ្វើការបែងចែកដូចតទៅ÷

**៤.១ សត្តឃាតដ្ឋានគោ-ក្របី:**

- ប្រភេទ "ក" ពិឃាតចាប់ពី ៥០ (ហាសិប) ក្បាលឡើងទៅ ក្នុងរយៈពេល២៤ (ម្ភៃបួន) ម៉ោង
- ប្រភេទ "ខ" ពិឃាតតិចជាង ៥០ (ហាសិប) ក្បាល ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង ។

**៤.២ សត្តឃាតដ្ឋានជ្រូក:**

- ប្រភេទ "ក" ពិឃាតចាប់ពី ១០០ (មួយរយ) ក្បាលឡើងទៅ ក្នុងរយៈពេល២៤ (ម្ភៃបួន) ម៉ោង
- ប្រភេទ "ខ" ពិឃាតតិចជាង ១០០ (មួយរយ) ក្បាល ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង ។

**៤.៣ សត្តឃាតដ្ឋានបក្សី:**

- ប្រភេទ "ក" ពិឃាតចាប់ពី ៥០០០ (ប្រាំពាន់) ក្បាលឡើងទៅ ក្នុងរយៈពេល២៤ (ម្ភៃបួន) ម៉ោង
- ប្រភេទ "ខ" ពិឃាតតិចជាង ៥០០០ (ប្រាំពាន់) ក្បាល ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង ។

ប្រភេទសត្តឃាតដ្ឋានដទៃទៀត ដែលមិនបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## មាត្រា ៥.-

សត្តឃាតដ្ឋាន ត្រូវមានទីតាំងនៅកន្លែងសមស្រប និង ត្រូវសាងសង់តាមបទដ្ឋានបច្ចេកទេស ដើម្បីធានាអនុវត្តវិធានបសុពេទ្យ អនាម័យ និង លក្ខខណ្ឌបច្ចេកទេសគ្រប់គ្រាន់សម្រាប់ការពិឃាតសត្វ ពិនិត្យសាច់ និង ផលិតផលសត្វ ។

ទីតាំង និង បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## មាត្រា ៦.-

ការបង្កើតសត្តឃាតដ្ឋាន និង ការធ្វើអាជីវកម្មពិឃាតសត្វគ្រប់ប្រភេទ ត្រូវមានលិខិតអនុញ្ញាតចេញដោយសមត្ថកិច្ចផលិតកម្ម និង បសុព្យាបាល ។

ចំពោះទីតាំងសម្រាប់ការសាងសង់សត្តឃាតដ្ឋានគ្រប់ប្រភេទ ត្រូវចុះទិដ្ឋាការពីអាជ្ញាធរ ខេត្ត ក្រុងសាមី ។

លិខិតអនុញ្ញាតបង្កើតសត្តឃាតដ្ឋានត្រូវបានផ្ដល់ដោយ:

ក- នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ដោយមានការឯកភាពជាគោលការណ៍ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចំពោះសត្តឃាតដ្ឋានក្នុងប្រភេទ " ក " ។

ខ- មន្ទីរកសិកម្ម តាមសំណើរបស់ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុងសាមី ចំពោះសត្តឃាតដ្ឋានក្នុងប្រភេទ " ខ " ដោយមានការឯកភាពជាគោលការណ៍ផ្នែកបច្ចេកទេស ពីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។

លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មពិឃាតសត្វគ្រប់ប្រភេទ ត្រូវបានផ្ដល់ដោយ:

ក- នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល តាមសំណើរបស់ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុងសាមី ចំពោះការធ្វើអាជីវកម្មពិឃាតសត្វ ក្នុងសត្តឃាតដ្ឋានប្រភេទ " ក " ។

ខ- ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុង ដោយមានទិដ្ឋាការពីមន្ទីរកសិកម្មខេត្ត ក្រុងនោះ ចំពោះការធ្វើអាជីវកម្មពិឃាតសត្វ ក្នុងសត្តឃាតដ្ឋានប្រភេទ " ខ " ។

គំរូលិខិតអនុញ្ញាត ទម្រង់ បែបបទសុំបង្កើតសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ និង បទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ៧.—**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានទទួលការអនុញ្ញាតឱ្យធ្វើអាជីវកម្មពិឃាតសត្វ មានកាតព្វកិច្ចដូចតទៅ÷

ក- ត្រូវប្រគល់ដល់ភ្នាក់ងារបសុពេទ្យនូវលិខិតដឹកជញ្ជូនសត្វ វិញ្ញាបនបត្រអនាម័យសត្វ អត្តសញ្ញាណប័ណ្ណសត្វ ឬ ភិនសត្វ ។

ខ- រក្សាទុកសត្វនៅកន្លែងបង្ខាំងសត្វ ក្នុងសត្តឃាតដ្ឋាន រយៈពេលពី១២ (ដប់ពីរ) ទៅ២៤ (ម្ភៃបួន) ម៉ោង មុនធ្វើការពិឃាត ដើម្បីឱ្យភ្នាក់ងារបសុពេទ្យត្រួតពិនិត្យសុខភាព ។

គ- បង្កភាពងាយស្រួលដល់ភ្នាក់ងារបសុពេទ្យត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន សត្វ សាច់ និង ផលិតផលសត្វ ឬ យកសំណាកសម្រាប់ធ្វើវិភាគ ។

ឃ-បង់កម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ស្របតាមមាត្រា ១៦ នៃ អនុក្រឹត្យនេះ ។

ង- ត្រូវអនុវត្តតាមបែបបទ និង បទបញ្ជាបសុពេទ្យ នៅពេលដឹកជញ្ជូនសាច់ និង ផលិតផលសត្វចេញពីសត្តឃាតដ្ឋាន ។ បែបបទ និង បទបញ្ជាបសុពេទ្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ៨.—**

ការធ្វើអាជីវកម្មពិឃាតសត្វ ត្រូវធ្វើនៅក្នុងសត្តឃាតដ្ឋាន ។ ការពិឃាតសត្វសម្រាប់ការពិសោធន៍ស្រាវជ្រាវ អាចធ្វើនៅក្រៅសត្តឃាតដ្ឋានបាន ដោយមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

**មាត្រា ៩.—**

ការធ្វើអាជីវកម្មពិឃាតសត្វ ត្រូវមានការអនុញ្ញាត ពីសមត្ថកិច្ចផលិតកម្ម និង បសុព្យាបាល ។

ការធ្វើអាជីវកម្មលក់សាច់ និង ផលិតផលសត្វ ត្រូវបោះត្រា អូសត្រា ឬ បិទស្លាកសម្គាល់ និង មានលិខិតបញ្ជាក់អនាម័យពីអង្គភាពផលិតកម្ម និង បសុព្យាបាល ។

ការលក់សាច់ និង ផលិតផលសត្វ ដែលមានប្រភពមេរោគបង្កជំងឺឆ្លងរាតត្បាត ឬ មានមេរោគបង្កជំងឺឆ្លងរាតត្បាតដល់សត្វ ឬ មនុស្ស ត្រូវហាមឃាត់ ។

ការក្លែងបន្លំត្រា ឬ ស្លាកសញ្ញារបស់អង្គភាពផលិតកម្ម និង បសុព្យាបាល សម្រាប់សម្គាល់ការត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វ ត្រូវហាមឃាត់ ។

# ជំពូកទី ៣

## សមត្ថកិច្ចត្រួតពិនិត្យ អនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និង កន្លែងតាំងលក់

**មាត្រា ១០.-**

ការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ និង ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមកន្លែងតាំងលក់ ត្រូវស្ថិតក្នុងដែនសមត្ថកិច្ចរបស់ការិយាល័យផលិតកម្ម និង បសុព្យាបាលនៃមន្ទីរកសិកម្ម ខេត្ត ក្រុង ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ។

ក្នុងករណីចាំបាច់ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល មានសមត្ថកិច្ចចុះត្រួតពិនិត្យការងារសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ តាមកន្លែងតាំងលក់នៅទូទាំងប្រទេស ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ។ ការចុះត្រួតពិនិត្យនេះ ត្រូវធ្វើជាលក្ខណៈរួមក្នុងពេលតែមួយលើក។

នីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

**មាត្រា ១១.-**

ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និង នៅតាមកន្លែងតាំងលក់ មានភារកិច្ចដូចតទៅ៖

**ក. ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចនៅតាមសត្តឃាតដ្ឋាន**

- ពិនិត្យអនាម័យសត្តឃាតដ្ឋាន
- ពិនិត្យលិខិតស្នាមដូចមានចែងក្នុងមាត្រា ៧ ចំណុច ក ពិនិត្យសត្វរស់មុនពិឃាត និង បង់លេខសម្គាល់សត្វ
- ពិនិត្យអនាម័យ កំណត់គុណភាពសាច់សត្វពិឃាតហើយ និង ផលិតផលសត្វ
- បោះ ឬ អូសត្រាលើផ្ទាំងសាច់ ឬ បិទស្លាកបសុពេទ្យលើកញ្ចប់សាច់ និង ផលិតផលសត្វ និង ចេញវិញ្ញាបនបត្របញ្ជាក់អនាម័យ
- ចាត់វិធានការបសុពេទ្យ ចំពោះការអនុវត្តផ្ទុយពីលក្ខខណ្ឌបច្ចេកទេស និង វេជ្ជបញ្ជាបសុពេទ្យ
- កត់ត្រាសត្វមុន និង ក្រោយពិឃាត បរិមាណសាច់ និង ផលិតផលសត្វ

**ខ. ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចនៅតាមកន្លែងតាំងលក់**

- ពិនិត្យវិញ្ញាបនបត្របញ្ជាក់អនាម័យសាច់ និង ផលិតផលសត្វ
- ពិនិត្យអនាម័យ គុណភាពសាច់ និង ផលិតផលសត្វ
- ពិនិត្យអនាម័យកន្លែងតាំងលក់សាច់ និង ផលិតផលសត្វ
- ចាត់វិធានការបសុពេទ្យ ចំពោះការអនុវត្តផ្ទុយពីលក្ខខណ្ឌបច្ចេកទេស និង បទប្បញ្ញត្តិបសុពេទ្យ

ប្រភេទត្រា ឬ ស្លាកបសុពេទ្យសម្រាប់សម្គាល់ការត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វនេះត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ១២.-**

ស្ថិតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ៦ និង ១០ នៃអនុក្រឹត្យនេះ អង្គភាពផលិតកម្ម និង បសុព្យាបាលមានសិទ្ធិ÷

- ណែនាំ ឬ ព្រមានជាលាយល័ក្ខណ៍អក្សរ
- ឃាត់ទុកនូវសត្វ សាច់ និង ផលិតផលសត្វ ដើម្បីអនុវត្តវិធានបសុពេទ្យ
- បង្វែរទិសដៅប្រើប្រាស់ ឬ កម្ទេចចោលសាច់ និង ផលិតផលសត្វ ខ្វះគុណភាព ឬ ខ្វះអនាម័យ ។ ការបង្វែរទិសដៅ និង ការកម្ទេចចោល អាចចាត់ចែងបានដោយភ្នាក់ងារបសុពេទ្យ លុះត្រាតែមានការអនុញ្ញាតពីស្ថាប័នរបស់ខ្លួន និង ការយល់ព្រមពីព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង
- បញ្ឈប់ជាបណ្ដោះអាសន្ន ឬ ជាស្ថាពរ នូវសត្តឃាតដ្ឋាន និង ការធ្វើអាជីវកម្មពិឃាតសត្វ ។

ក្នុងករណីមានបទល្មើស ត្រូវធ្វើកំណត់ហេតុ និង ចងក្រងសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ១៣.-**

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជួយផ្តល់អន្តរាគមន៍ ក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ ក្នុងការបង្ក្រាបបទល្មើសពាក់ព័ន្ធនិងអនាម័យសត្តឃាតដ្ឋាន សត្វ សាច់ និង ផលិតផលសត្វ ក្នុងករណីមានការស្នើសុំពីភ្នាក់ងារបសុពេទ្យ ។

## ជំពូកទី ៤

## ឯកសណ្ឋាន និង សញ្ញាសម្គាល់ ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច សម្លៀកបំពាក់អ្នកពិឃាតសត្វ និង អ្នកបំពេញការងារនៅសត្តឃាតដ្ឋាន

**មាត្រា ១៤.-**

ក្នុងពេលប្រតិបត្តិការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន សត្វ សាច់ និង ផលិតផលសត្វ ភ្នាក់ងារបសុពេទ្យនៅសត្តឃាតដ្ឋាន និង ភ្នាក់ងារបសុពេទ្យដែលត្រូវបានចាត់តាំងឱ្យចុះត្រួតពិនិត្យ តាមកន្លែងតាំងលក់សាច់ និង ផលិតផលសត្វ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ និង មានលិខិតបញ្ជាបេសកកម្មជាប់នឹងខ្លួន។

**មាត្រា ១៥.-**

អ្នកពិឃាតសត្វ និង អ្នកបំពេញការងារនៅក្នុងសត្តឃាតដ្ឋាន ត្រូវស្លៀកពាក់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដើម្បីធានាសុវត្ថិភាព និង រក្សាអនាម័យ តាមបទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន។

## ជំពូកទី ៥

## ការប្រមូលកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅសត្តឃាតដ្ឋាន

**មាត្រា ១៦.-**

ភ្នាក់ងារបសុពេទ្យដែលមានសមត្ថកិច្ចប្រចាំការនៅសត្តឃាតដ្ឋាន ត្រូវប្រមូលកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ដើម្បីបង់ចូលថវិកាខេត្ត ក្រុង។

កម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

**មាត្រា ១៧.-**

នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល មានភារកិច្ចត្រួតពិនិត្យ ការអនុវត្តយកកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ របស់ការិយាល័យផលិតកម្ម និង បសុព្យាបាល នៃមន្ទីរកសិកម្ម ខេត្ត ក្រុង។

**មាត្រា ១៨.-**

រង្វាន់លើកទឹកចិត្តដល់មន្ត្រី ដែលបានចូលរួមបង្ក្រាបបទល្មើស ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ១៩.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមមាត្រា ៦២ ជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និង សេវា ។

**មាត្រា ២០.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងមាត្រា ៨ និងមាត្រា ៩ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមមាត្រា ៦៣ ជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និង សេវា ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ២១.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានបង្កើតសត្តឃាតដ្ឋាន ឬ ធ្វើអាជីវកម្មពិឃាតសត្វនៅមុនពេលអនុក្រឹត្យនេះចូលជាធរមាន ក្រោមសុពលភាពនៃលិខិតអនុញ្ញាត ដែលបានផ្តល់ឱ្យដោយអនុលោមតាមអនុក្រឹត្យលេខ ២៩ អនក្រ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ឬ ដោយអនុលោមតាមលិខិតបទដ្ឋានណាផ្សេងក្តី ត្រូវបានអនុញ្ញាតឱ្យបន្តសុពលភាពក្នុងរយៈពេលមិនលើសពី ០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃអនុក្រឹត្យនេះចូលជាធរមាន ។ នៅក្នុងចិរវេលានេះ សាមីបុគ្គលនោះត្រូវបំពេញបែបបទសុំបង្កើតសត្តឃាតដ្ឋាន ឬ ការធ្វើអាជីវកម្មពិឃាតសត្វជាថ្មី ស្របតាមនីតិវិធី ដូចមានចែងក្នុងអនុក្រឹត្យនេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២២.-**

អនុក្រឹត្យលេខ ២៩ អនក្រ. ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ស្តីពីសត្តឃាតដ្ឋាន និង កន្លែងពិឃាតសត្វ និង បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ សីហា ឆ្នាំ ២០០៧

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ២៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ